
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ក្រសួងសាធារណការ និងដឹកជញ្ជូន

សម្រេច

មាត្រា១.- បំពាក់មេដាយ**សុវត្ថារា** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន ៩៥រូប នៃក្រសួងសាធារណការ និងដឹកជញ្ជូន ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ**សុវត្ថារា** ថ្នាក់ **ធិបឌិន្ទ**

១-	លោក	ឈុយ ច័ន្ទដារ៉ា	អគ្គនាយករង នៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក
២-	លោកស្រី	ឡឹក សាម៉ុល	អនុប្រធាននាយកដ្ឋានព័ត៌មានភស្តុភារកម្ម
៣-	លោក	ឃ្លាំង សុខា	អនុប្រធាននាយកដ្ឋានព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ
៤-	លោក	ទេស តារារ័ត្ន	អនុប្រធាននាយកដ្ឋានព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ
៥-	លោកស្រី	ប៊ុន សុគន្ធារ៉ា	អនុប្រធាននាយកដ្ឋានព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ
៦-	លោក	អ៊ុក រតនា	ប្រធានការិ.កិច្ចការទូទៅ នៃនាយកដ្ឋានបុគ្គលិក
៧-	លោក	ហូ ពេជ្រប្រមា	ប្រធានការិ.បណ្តុះបណ្តាល នៃនាយកដ្ឋានបុគ្គលិក
៨-	លោក	សេង គឹមសាន	អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានីភ្នំពេញ
៩-	លោក	ពេញ សាវុឌ្ឍ	ប្រធានការិ.ផែនការ និងហិរញ្ញវត្ថុ នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តមណ្ឌលគិរី
១០-	លោកស្រី	ហៃ សុគន្ធា	អនុប្រធានការិ.បៀវត្ស នៃនាយកដ្ឋានបុគ្គលិក
១១-	លោក	ធុយ វណ្ណា	ប្រធានការិ.ដឹកជញ្ជូនផ្លូវគោក នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកណ្តាល
១២-	លោក	ព្រំ វ៉ាន់ឌី	ប្រធានការិ.សុវត្ថិភាពចរាចរណ៍ នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកំពង់ធំ
១៣-	លោក	យ៉ន ង៉ុក	ប្រធានការិ.លូទឹក និងស្ថានីយចម្រោះទឹកកខ្វក់ នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកំពង់ធំ

១៤- លោក សើ គីមឈីវ ប្រធានការិ.ដឹកជញ្ជូនផ្លូវទឹក និងកំពង់ផែ នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកំពង់ធំ

១៥- លោក ជួ សឿម ប្រធានការិ.ផែនការ និងហិរញ្ញវត្ថុ នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តពោធិ៍សាត់

១៦- លោក ម៉ែន សុខា ប្រធានការិ.កិច្ចការទូទៅ នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តព្រះសីហនុ

ខ-មេដាយ**សុវត្ថារា** ថ្នាក់ **សេនា**

១- លោកស្រី ឯក ម៉ានីកា អគ្គនាយករង នៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ

២- លោក នូ ផល្លា អធិការ នៃអគ្គាធិការដ្ឋាន

៣- លោក នូ វិចិត្រ អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

៤- លោកស្រី ជា សាវ៉ុន អនុប្រធាននាយកដ្ឋានរដ្ឋបាលកំពង់ផែ

៥- លោក អៀន ឈុត អនុប្រធាននាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក និងសំណង់កំពង់ផែ

៦- លោកស្រី ទីន ណូតទីយ៉ាស់ អធិការរង នៃអគ្គាធិការដ្ឋាន

៧- លោក ជូ គីមទ្រី អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានីភ្នំពេញ

៨- លោកស្រី ភុយ នីន ប្រធានការិ.កិច្ចការទូទៅ នៃនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក និងសំណង់កំពង់ផែ

៩- លោក ខេង សុមេធា ប្រធានការិ.ស្រាវជ្រាវបណ្តុះបណ្តាលបច្ចេកទេសផ្លូវថ្នល់នៃនាយកដ្ឋានជួសជុលនិងថែទាំផ្លូវថ្នល់

១០- លោក គង្គ យាង អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកំពង់ឆ្នាំង

១១- លោក ម៉ឺន សុវណ្ណនី អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តមណ្ឌលគិរី

១២- លោក អ៊ុយ សុវណ្ណារិទ្ធ អនុប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោក

១៣- លោក រឿង អមរា អនុប្រធានអង្គភាពសាងសង់ជួសជុល និងថែទាំថ្នល់នៃនាយកដ្ឋានជួសជុល និងថែទាំផ្លូវថ្នល់

១៤- លោក លាង ឆាយ អនុប្រធានអង្គភាពអន្តរាគមន៍បន្ទាន់ នៃនាយកដ្ឋានជួសជុល និងថែទាំផ្លូវថ្នល់

១៥- លោក ស៊ុន ហួត អនុប្រធានការិ.គ្រប់គ្រងគ្រឿងចក្រ និងសម្ភារផ្លូវថ្នល់ នៃនាយកដ្ឋានជួសជុល និងថែទាំផ្លូវថ្នល់

១៦- លោកស្រី ជា តាំងអ៊ី ប្រធានការិ.កិច្ចការទូទៅ នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកំពង់ធំ

១៧- លោក គីម សុវណ្ណ ប្រធានការិ.ផែនការ និងហិរញ្ញវត្ថុ នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកែប

១៨- លោក លឹម ធាតុង ប្រធានការិ.សាធារណការ នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកែប

១៩- លោក អ៊ុក សារឿន ប្រធានការិ.ដឹកជញ្ជូនផ្លូវគោក នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកែប

២០- លោកស្រី ដា សូរីយា អនុប្រធានការិ.ដឹកជញ្ជូនផ្លូវគោក នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកំពង់ធំ

២១- លោក យក់ សំអឿន ប្រធានការិ.សាធារណការ និងដឹកជញ្ជូនស្រុកខ្សាច់កណ្តាល នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកណ្តាល

២២- លោក មាស ហាក់ ប្រធានការិ.សាធារណការ និងដឹកជញ្ជូនស្រុកកោះធំ នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកណ្តាល

២៣- លោក នី នៃល ប្រធានសេវាដ្ឋានផ្តល់ប័ណ្ណបើកបរ នៃមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកណ្តាល

២៤- លោក ញ៉ាញ់ នឿន អនុប្រធានការិ.ផែនការ និងហិរញ្ញវត្ថុ នៃមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះសីហនុ

២៥- លោក ប៊ុន សំអូន ប្រធានការិ.ដឹកជញ្ជូនផ្លូវសមុទ្រ និងកំពង់ផែ នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តព្រះសីហនុ

២៦- លោកស្រី ដួច គន្ធា អនុប្រធានការិ.ផែនការ និងហិរញ្ញវត្ថុ នៃមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តមណ្ឌលគិរី

២៧- លោក សែម ឈិន អនុប្រធានការិ.ផែនការ និងហិរញ្ញវត្ថុ នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកែប

២៨- លោកស្រី ឈ្លូក បូរី អនុប្រធានការិ.ផែនការ និងហិរញ្ញវត្ថុ នៃមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកែប

គ-មេដាយ**សុវត្ថារា** ថ្នាក់ **អស្សឫទ្ធិ**

១- លោក សែម បញ្ញា អនុប្រធាននាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក និងសំណង់កំពង់ផែ

២- លោក ចំរើន សេរីរិទ្ធ អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តឧត្តរមានជ័យ

៣-	លោក	សុខ ចំរើន	ប្រធានការិ.សរុប នៃនាយកដ្ឋានរដ្ឋបាល
៤-	លោក	លន់ វិរៈវិចិត្រា	ប្រធានការិ.ផែនការបច្ចេកទេស នៃនាយកដ្ឋានជួសជុល និងថែទាំផ្លូវថ្នល់
៥-	លោក	ស ផូ	ប្រធានការិ.អាជីវកម្មដឹកជញ្ជូនផ្លូវទឹក នៃនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក
៦-	លោក	ហ៊ីម សុខុម	ប្រធានការិ.ទ្រព្យធន នៃនាយកដ្ឋានផ្លូវដែក
៧-	លោក	ម៉ុម សុខាន	ប្រធានការិ.ផែនការ និងហិរញ្ញវត្ថុ នៃមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានីភ្នំពេញ
៨-	លោក	ធីម វ៉េ	ប្រធានការិ.ដឹកជញ្ជូនផ្លូវគោក នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកំពង់ចាម
៩-	លោក	ទុយ ស្រ៊ុន	ប្រធានការិ.សុវត្ថិភាពចរាចរណ៍ នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកំពង់ចាម
១០-	លោកស្រី	ប៉ៃ សុផាន្នី	អនុប្រធានការិ.គ្រប់គ្រងបុគ្គលិក នៃនាយកដ្ឋានបុគ្គលិក
១១-	លោក	ស្លូង សេដ្ឋា	អនុប្រធានការិ.សណ្តាប់ធ្នាប់ នៃនាយកដ្ឋានរដ្ឋបាល
១២-	លោក	ឈុំ សុខ	អនុប្រធានការិ.ផែនការ និងបច្ចេកទេស នៃនាយកដ្ឋានផ្លូវថ្នល់
១៣-	លោក	ង៉ីម នូបា	អនុប្រធានការិ.គ្រប់គ្រងកិច្ចការអាជីវកម្មផ្លូវថ្នល់ នៃនាយកដ្ឋានផ្លូវថ្នល់
១៤-	លោក	ឈាង ច័ន្ទដារិទ្ធ	អនុប្រធានការិ.សារពើភ័ណ្ឌផ្លូវថ្នល់ នៃនាយកដ្ឋានផ្លូវថ្នល់
១៥-	លោក	ចាន់ តារា	អនុប្រធានការិ.គម្រោងផ្លូវដែកទីក្រុង នៃនាយកដ្ឋានផ្លូវដែក
១៦-	លោក	ម៉េង បូរិន្ទ	អនុប្រធានការិ.ផែនការ និងបច្ចេកទេស នៃនាយកដ្ឋានជួសជុល និងថែទាំផ្លូវថ្នល់
១៧-	លោក	ហ៊ិន ពេញ	អនុប្រធានអង្គភាពអន្តរាគមន៍សាធារណការ នៃនាយកដ្ឋានគ្រឿងចក្រ និងស្ពានបនាផ្លូវ
១៨-	លោក	ជា សាត	អនុប្រធានអង្គភាពអន្តរាគមន៍សាធារណការ នៃនាយកដ្ឋានគ្រឿងចក្រ និងស្ពានបនាផ្លូវ
១៩-	លោក	ឈង វណ្ណថា	អនុប្រធានការិ.សណ្តាប់ធ្នាប់សាធារណការ នៃមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានីភ្នំពេញ
២០-	លោក	ឱ ចាន់ណារ៉ា	អនុប្រធានការិ.លូទឹក និងស្ថានីយចម្រោះទឹកកខ្វក់ នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកណ្តាល
២១-	លោកស្រី	ព្រំ សុខេង	អនុប្រធានការិ.សាធារណការ និងដឹកជញ្ជូនស្រុកមុខកំពូល នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកណ្តាល
២២-	លោក	ហួរ ប៊ុនធឿន	អនុប្រធានការិ.ដឹកជញ្ជូនផ្លូវគោក នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកំពង់ចាម
២៣-	លោក	ខិ ប៉េងអ៊ីវ	ប្រធានការិ.សាធារណការ និងដឹកជញ្ជូនស្រុកប្រាសាទបល្ល័ង្ក នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកំពង់ធំ
២៤-	លោក	ឈុន វណ្ណនី	អនុប្រធានការិ.សាធារណការ និងដឹកជញ្ជូនស្រុកបារាយណ៍ នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកំពង់ធំ
២៥-	លោក	សុខ ផាន	ប្រធានការិ.សាធារណការ និងដឹកជញ្ជូនស្រុកសំរោង នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តតាកែវ
២៦-	លោក	ឃាង វុទ្ធី	អនុប្រធានការិ.សាធារណការ និងដឹកជញ្ជូនស្រុកសំរោង នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តតាកែវ
២៧-	លោក	ពេជ្រ ភារី	ប្រធានការិ.លូទឹក និងស្ថានីយចម្រោះទឹកកខ្វក់ នៃមន្ទីរសាធារណការនិងដឹកជញ្ជូន ខេត្តព្រះសីហនុ
២៨-	លោក	នៅ ជា	អនុប្រធានការិ.កិច្ចការទូទៅ នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តព្រះសីហនុ
២៩-	លោកស្រី	ប៉ែត ប៊ុណ្ណារី	អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តព្រះសីហនុ
៣០-	លោក	សុខ ប៊ុនសុន	ប្រធានការិ.សាធារណការនិងដឹកជញ្ជូនក្រុងប៉ៃលិននៃមន្ទីរសាធារណការនិងដឹកជញ្ជូន ខេត្តប៉ៃលិន
៣១-	លោក	នៅ ណុន	អនុប្រធានការិ.ដឹកជញ្ជូនផ្លូវគោក នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តរតនគិរី
៣២-	លោក	ហាក់ មុន្នី	អនុប្រធានការិ.សណ្តាប់ធ្នាប់សាធារណៈ នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តរតនគិរី
៣៣-	លោក	ហាក់ ធីម	អនុប្រធានការិ.សាធារណការ នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកែប
៣៤-	លោក	គុំ ផាត	មន្ត្រីអង្គភាពសាងសង់ជួសជុល និងថែទាំស្ពាន នៃនាយកដ្ឋានជួសជុល និងថែទាំផ្លូវថ្នល់
៣៥-	លោក	អំណាត់ វិរិយា	មន្ត្រីអង្គភាពសាងសង់ជួសជុល និងថែទាំស្ពាន នៃនាយកដ្ឋានជួសជុល និងថែទាំផ្លូវថ្នល់

៣៦- លោក	ឃុត ចាន់ធូ	មន្ត្រីអង្គភាពសាងសង់ផ្លូវថ្នល់ និងថែទាំស្ពាន នៃនាយកដ្ឋានផ្លូវថ្នល់ និងថែទាំផ្លូវថ្នល់
៣៧- លោក	ជា គៀង	មន្ត្រីអង្គភាពសាងសង់ផ្លូវថ្នល់ និងថែទាំស្ពាន នៃនាយកដ្ឋានផ្លូវថ្នល់ និងថែទាំផ្លូវថ្នល់
៣៨- លោក	ទូច សាម៉ន	មន្ត្រីអង្គភាពសាងសង់ផ្លូវថ្នល់ និងថែទាំស្ពាន នៃនាយកដ្ឋានផ្លូវថ្នល់ និងថែទាំផ្លូវថ្នល់
៣៩- លោក	វី លន់	មន្ត្រីអង្គភាពសាងសង់ផ្លូវថ្នល់ និងថែទាំស្ពាន នៃនាយកដ្ឋានផ្លូវថ្នល់ និងថែទាំផ្លូវថ្នល់
៤០- លោក	សេន ស៊ីវ៉ាដា	មន្ត្រីអង្គភាពសាងសង់ផ្លូវថ្នល់ និងថែទាំស្ពាន នៃនាយកដ្ឋានផ្លូវថ្នល់ និងថែទាំផ្លូវថ្នល់
៤១- លោក	សី សារុន	មន្ត្រីអង្គភាពសាងសង់ផ្លូវថ្នល់ និងថែទាំស្ពាន នៃនាយកដ្ឋានផ្លូវថ្នល់ និងថែទាំផ្លូវថ្នល់
៤២- លោក	ម៉ុល ដា	មន្ត្រីអង្គភាពសាងសង់ផ្លូវថ្នល់ និងថែទាំស្ពាន នៃនាយកដ្ឋានផ្លូវថ្នល់ និងថែទាំផ្លូវថ្នល់
៤៣- លោក	សុខ វ៉េត	មន្ត្រីអង្គភាពសាងសង់ផ្លូវថ្នល់ និងថែទាំស្ពាន នៃនាយកដ្ឋានផ្លូវថ្នល់ និងថែទាំផ្លូវថ្នល់
៤៤- លោក	ព្រំ សន	មន្ត្រីអង្គភាពស្ថាបនាថ្នល់ នៃនាយកដ្ឋានគ្រឿងចក្រ និងស្ថាបនាផ្លូវ
៤៥- លោក	ប៊ុន សុខនឿន	មន្ត្រីអង្គភាពស្ថាបនាថ្នល់ នៃនាយកដ្ឋានគ្រឿងចក្រ និងស្ថាបនាផ្លូវ
៤៦- លោក	តឹម ប៊ុយ	មន្ត្រីអង្គភាពស្ថាបនាថ្នល់ នៃនាយកដ្ឋានគ្រឿងចក្រ និងស្ថាបនាផ្លូវ
៤៧- លោក	មាន់ ពុំ	មន្ត្រីអង្គភាពស្ថាបនាថ្នល់ នៃនាយកដ្ឋានគ្រឿងចក្រ និងស្ថាបនាផ្លូវ
៤៨- លោក	វុធ ថា	ប្រធានផ្នែកគណនេយ្យការិ.ស្ពានថ្នល់ និងរុក្ខជាតិ នៃមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានីភ្នំពេញ
៤៩- លោក	យឹម អឿន	មន្ត្រីការិ.សាធារណការ នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកណ្ដាល
៥០- លោក	ទួន ភន	មន្ត្រីការិ.សាធារណការ នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកណ្ដាល
៥១- លោក	ឱម គន្ធ	មន្ត្រីការិ.សាធារណការ នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកោះកុង

មាត្រា២..រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសារណៈ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១ រោច ខែ ស្រាពណ៍ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០២១

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ...៨៥...សសរ

សេចក្តីសម្រេច

ស្តីពី

ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីគ្រប់គ្រងចំណូលដែលបានមកពីការផ្ទេរ ផ្ទៃដីទំហំ ១០០ហិកតា ស្ថិតនៅសង្កាត់ពញាពន់ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ សម្រាប់ចំណាយលើការងារសាងសង់អគារទីស្តីការថ្មីរបស់ក្រសួងមហាផ្ទៃ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១២៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១ ស្តីពីការកែសម្រួលផ្ទៃបឹងតាមោក(បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ
- យោងលិខិតលេខ ៤១០ សជណ.មយ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

ប្រការ ១.-

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីគ្រប់គ្រងចំណូលដែលបានមកពីការផ្ទេរផ្ទៃដីទំហំ ១០០ ហិកតា ស្ថិតនៅសង្កាត់ពញាពន់ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ សម្រាប់ចំណាយលើការងារសាងសង់អគារទីស្តីការថ្មីរបស់ក្រសួងមហាផ្ទៃ ដែលមានសមាសភាពមកពីក្រសួង ស្ថាប័នពាក់ព័ន្ធដូចខាងក្រោមៈ

១.អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ	ប្រធាន
២.អគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	អនុប្រធាន
៣.អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ	អនុប្រធាន
៤. អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ	អនុប្រធាន

៥. អភិបាលរងមួយរូបនៃគណៈអភិបាលរាជធានីភ្នំពេញ សមាជិក

៦. នាយករដ្ឋបាលសាលារាជធានីភ្នំពេញ សមាជិក

ប្រការ ២.-

គណៈកម្មការនេះមានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ចុះពិនិត្យ និងវាស់វែងផ្ទៃដីទំហំ ១០០ ហិកតា ស្ថិតនៅសង្កាត់ពញាពន់ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ
- រៀបចំបំពេញបែបបទ និងនីតិវិធីស្នើសុំប័ណ្ណកម្មសិទ្ធិផ្ទៃដីទំហំ ១០០ហិកតាខាងលើជូនក្រសួងមហាផ្ទៃ ស្របតាមនីតិវិធីសុរិយោដី
- ពិនិត្យ និងវាយតម្លៃចំពោះតម្លៃអចលនទ្រព្យលើផ្ទៃដីទំហំ ១០០ហិកតា
- ស្វែងរក និងកំណត់បុគ្គល ឬក្រុមហ៊ុន ឬវិស័យឯកជនដែលមានសក្តានុពលធ្វើជាដៃគូក្នុងការផ្ទេរកម្មសិទ្ធិផ្ទៃដីទំហំ ១០០ហិកតាខាងលើ ដើម្បីយកថវិកាមកចំណាយលើការងារសាងសង់អគារទីស្តីការថ្មីរបស់ក្រសួងមហាផ្ទៃ
- ពិនិត្យ និងដោះស្រាយការងារចាំបាច់ផ្សេងៗទៀតដែលពាក់ព័ន្ធនឹងផ្ទៃដីទំហំ ១០០ហិកតា
- ធ្វើរបាយការណ៍អំពីវឌ្ឍនភាពការងារទាំងអស់ខាងលើជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីគោរពជូនជ្រាប និងគោរពស្នើសុំអនុសាសន៍ដឹកនាំបន្តដ៏ខ្ពង់ខ្ពស់ជាយថាហេតុ។

ប្រការ ៣.-

គណៈកម្មការនេះមានសិទ្ធិបង្កើតអនុគណៈកម្មការមួយចំនួន ដើម្បីជួយសម្រួលដល់ការងារ និងមានសិទ្ធិប្រើប្រាស់ជាផ្លូវការនូវត្រារបស់រដ្ឋបាលរាជធានីភ្នំពេញ។

ប្រការ ៤.-

អនុប្រធាន និងសមាជិកនៃគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ប្រការ ៥.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ និងឯកឧត្តម អស់លោក ដែលមានរាយនាមក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ១៨ រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>**កន្លែងទទួល៖**</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៩០ សសរ

សេចក្តីសម្រេច

ស្តីពី

ការចាត់តាំងរដ្ឋលេខាធិការប្រចាំការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦២០/៦១១ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការតែងតាំងរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីតួនាទី និងភារកិច្ចរបស់រដ្ឋលេខាធិការប្រចាំការ
- បានឃើញអនុក្រឹត្យលេខ១១៩ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់រដ្ឋមន្ត្រីស្តីទី
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

សម្រេច

ប្រការ១ : ចាត់តាំងឯកឧត្តម **ជាម សត្ថារតន៍** ជារដ្ឋលេខាធិការប្រចាំការនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ប្រការ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៥ រោច ខែ ស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...០៦...សណន

សេចក្ដីណែនាំ

ស្ដីពី

ការពង្រឹងការអនុវត្តយុទ្ធនាការជាតិចាក់វ៉ាក់សាំងកូវីដ-១៩ ជុំទី១

រាជរដ្ឋាភិបាលបានដាក់ចេញ និងកំពុងអនុវត្តយ៉ាងសកម្មនូវគោលនយោបាយចាក់វ៉ាក់សាំងកូវីដ-១៩ ដែលត្រូវបានចាត់ទុកជាយុទ្ធសាស្ត្រគន្លឹះដ៏សំខាន់មួយ និងជាខ្សែក្រវាត់ការពារទី១ ដើម្បីការពារអាយុជីវិតប្រជាជន ក៏ដូចជាដើម្បីបង្កើតឱ្យបាននូវភាពស៊ាំសហគមន៍ទប់ទល់នឹងមេរោគកូវីដ-១៩ សំដៅឈានឆ្ពោះទៅបើកដំណើរការប្រទេសជាតិពេញលេញឡើងវិញលើគ្រប់វិស័យ និងការរស់នៅជាមួយនឹងជំងឺនេះតាមគន្លងប្រក្រតីភាពថ្មី។ គិតមកទល់ពេលនេះ, ព្រះរាជាណាចក្រកម្ពុជាសម្រេចបានការចាក់វ៉ាក់សាំងជូនប្រជាជនដែលមានអាយុចាប់ពី ១២ ឆ្នាំឡើងទៅ បានប្រមាណ ៨៩% ធៀបនឹងគោលដៅប្រមាណ ១២ លាននាក់។ យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ជុំទី១ ត្រូវបានរំពឹងថា នឹងអាចបញ្ចប់នៅចុងខែតុលា ឬដើមខែវិច្ឆិកាខាងមុខនេះ មុនផែនការដែលបានគ្រោងទុក។ បន្ថែមពីលើនេះ, រាជរដ្ឋាភិបាល ក៏បានដាក់ចេញនូវ **"គោលនយោបាយចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ"** ជូនប្រជាជន ដើម្បីធានាឱ្យបាននូវ **"ភាពស៊ាំសហគមន៍រឹងមាំពិតប្រាកដមួយ"** សំដៅទប់ទល់នឹងការវាយលុកនៃមេរោគប្រភេទ Delta ក្នុងសហគមន៍ និងការត្រៀមលក្ខណៈសម្រាប់ការឈានឆ្ពោះទៅកាន់ផែនការបើកដំណើរការប្រទេសពេញឡើងវិញលើគ្រប់វិស័យ និងការរស់នៅជាមួយជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី។

លើមូលដ្ឋាននៃវឌ្ឍនភាពដ៏ល្អប្រសើរខាងលើនេះ និងក្នុងគោលបំណងបង្កើនល្បឿននៃការចាក់វ៉ាក់សាំងឱ្យបានឆាប់រហ័ស និងអាចឈានទៅបិទបញ្ចប់យុទ្ធនាការជាតិចាក់វ៉ាក់សាំងកូវីដ-១៩ ជុំទី១ នាពេលដ៏ខ្លីខាងមុខនេះ, **រាជរដ្ឋាភិបាល** សូមធ្វើការណែនាំដល់គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស, គណៈអភិបាលរាជធានី-ខេត្ត និងយន្តការដែលមានការពាក់ព័ន្ធផ្សេងទៀត ឱ្យយកចិត្តទុកដាក់ក្នុងការពង្រឹងការអនុវត្តការងារមួយចំនួនបន្ថែមទៀត ដូចខាងក្រោម៖

១-គណៈអភិបាលរាជធានី-ខេត្ត ត្រូវប្រមូលផ្តុំការយកចិត្តទុកដាក់ និងការខិតខំប្រឹងប្រែងលើការប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដោយចាត់ទុកជាការងារស្នូលអាទិភាពខ្ពស់បំផុតរបស់ខ្លួនជាពិសេស ត្រូវសម្រេចឱ្យបានឆាប់រហ័សនូវការចាក់វ៉ាក់សាំងជូនប្រជាជននៅក្នុងមូលដ្ឋានក្រោមសមត្ថកិច្ចរបស់ខ្លួន ដែលជាខ្សែក្រវាត់ការពារទី១ និងជាយុទ្ធសាស្ត្រគន្លឹះរបស់រាជរដ្ឋាភិបាល ក្នុងសមរភូមិប្រយុទ្ធនឹងជំងឺកូវីដ-១៩។ ទន្ទឹមនេះ គណៈអភិបាលរាជធានី-ខេត្ត ត្រូវរាយការណ៍ប្រចាំថ្ងៃ និងជាប់ជាប្រចាំអំពីវឌ្ឍនភាពនៃការគ្រប់គ្រង និងការអនុវត្តការងារចាក់វ៉ាក់សាំងកូវីដ-១៩ នៅក្នុងមូលដ្ឋានក្រោមសមត្ថកិច្ចរបស់ខ្លួន ជូន

គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំង ដើម្បីជាមូលដ្ឋានក្នុងការតាមដាន និងត្រួតពិនិត្យការងារចាក់វ៉ាក់សាំង ដោយប្រើប្រាស់គំរូតារាងព័ត៌មាន ដែលត្រូវបានរៀបចំដោយគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស។

២-គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស ត្រូវពង្រឹងយន្តការតាមដាន និងត្រួតពិនិត្យរបស់ខ្លួនលើវឌ្ឍនភាពនៃការអនុវត្តការងារចាក់វ៉ាក់សាំងកូវីដ-១៩ ប្រចាំថ្ងៃ ទាំងសម្រាប់ក្របខណ្ឌរាជធានី-ខេត្តនីមួយៗដាច់ដោយឡែកពីគ្នា ទាំងសម្រាប់ក្របខណ្ឌទូទាំងប្រទេស ព្រមទាំងត្រូវពង្រឹងយន្តការឆ្លើយតបឱ្យបានទាន់ពេលវេលា ទាក់ទងនឹងការអនុវត្តយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនប្រជាជនជាក់ស្តែងនៅតាមមូលដ្ឋាន ជាពិសេស ការសម្របសម្រួលក្រុមគ្រូពេទ្យចាក់វ៉ាក់សាំងឱ្យត្រូវទៅនឹងស្ថានភាពជាក់ស្តែងនៅក្នុងមូលដ្ឋាននីមួយៗ និងការធានាផ្គត់ផ្គង់ឱ្យបានទាន់ពេលវេលា និងមិនត្រូវខ្វះវ៉ាក់សាំងជូនដល់បណ្តារាជធានី-ខេត្ត ដើម្បីចាក់ជូនប្រជាជនដោយផ្អែកតាមតម្រូវការជាក់ស្តែងក្នុងភូមិសាស្ត្រនីមួយៗ និងតាមអភិក្រម "**មិនអនុញ្ញាតឱ្យមានវ៉ាក់សាំងដេកក្នុងឃ្លាំង ក្នុងពេលដែលប្រជាជនត្រូវការវ៉ាក់សាំងនោះទេ**"។

៣-គណៈអភិបាលរាជធានី-ខេត្ត ត្រូវរៀបចំធ្វើបច្ចុប្បន្នកម្មឡើងវិញឱ្យបានច្បាស់លាស់ និងឆាប់រហ័សអំពីចំនួនប្រជាជនជាក់ស្តែងនៅមូលដ្ឋានដែលត្រូវចាក់វ៉ាក់សាំងកូវីដ-១៩ ជាពិសេស នៅកម្រិតថ្នាក់ឃុំ-សង្កាត់ និងញែកចេញចំនួនប្រជាជនចំណាកស្រុក ដែលអាចទទួលការចាក់វ៉ាក់សាំងកូវីដ-១៩ នៅទីកន្លែងផ្សេង ដើម្បីមានមូលដ្ឋានច្បាស់លាស់ ក្នុងការកែសម្រួលផែនការចាក់វ៉ាក់សាំងដោយផ្អែកតាមចំនួនប្រជាជនជាក់ស្តែងនៅក្នុងមូលដ្ឋាន ក៏ដូចជាឈានទៅសម្រេចបិទបញ្ចប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នៅមូលដ្ឋាននោះ។ ប៉ុន្តែ មុននឹងសម្រេចបិទបញ្ចប់យុទ្ធនាការចាក់វ៉ាក់សាំងនៅមូលដ្ឋាននីមួយៗ និងចល័តទៅកាន់ទីកន្លែងផ្សេងទៀត, ក្រុមការងារយុទ្ធនាការចាក់វ៉ាក់សាំងនៅតាមមូលដ្ឋាននីមួយៗ ត្រូវធ្វើការជូនដំណឹងជាសាធារណៈអំពីការត្រៀមបិទបញ្ចប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នេះ និងត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីសម្រេចបិទបញ្ចប់យុទ្ធនាការចាក់វ៉ាក់សាំងនៅទីតាំងមូលដ្ឋាននោះ។ ទន្ទឹមនេះ បន្ទាប់ពីការបញ្ចប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នៅតាមមូលដ្ឋាននីមួយៗ និងដើម្បីធានាដល់ការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការចាក់វ៉ាក់សាំងកូវីដ-១៩ នេះ ឱ្យបានគ្រប់គ្នាជូនដល់ប្រជាជនដែលមានលក្ខណៈសម្បត្តិអាចចាក់វ៉ាក់សាំងបាន, គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស និងគណៈអភិបាលរាជធានី-ខេត្ត ត្រូវសហការគ្នាកំណត់អំពីទីតាំងសម្រាប់ការផ្តល់សេវាចាក់វ៉ាក់សាំងជូនដល់ប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅតាមមន្ទីរពេទ្យបង្អែកក្រុង-ស្រុក-ខណ្ឌ ឬនៅតាមមណ្ឌលសុខភាព (ផ្អែកតាមស្ថានភាពនៃភូមិសាស្ត្រជាក់ស្តែងនីមួយៗ) និងត្រូវជូនដំណឹងជាសាធារណៈ ដើម្បីអនុញ្ញាតឱ្យប្រជាជនដែលមិនទាន់បានទទួលការចាក់វ៉ាក់សាំង អាចទៅទទួលការចាក់វ៉ាក់សាំងនេះបាននៅតាមទីតាំងកំណត់នោះ។

៤-សម្រាប់ក្របខណ្ឌទូទាំងប្រទេស, ផ្អែកលើមូលដ្ឋាននៃវឌ្ឍនភាពនៃការចាក់វ៉ាក់សាំងលើចំនួនជាក់ស្តែងនៃប្រជាជននៅមូលដ្ឋាន និងលទ្ធផលនៃការធ្វើបច្ចុប្បន្នកម្មចំនួនប្រជាជននៅតាមបណ្តារាជធានី-ខេត្ត, គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស ត្រូវធ្វើការបូកសរុប និងវាយតម្លៃ ដើម្បីស្នើសុំគោលការណ៍សម្រេចពីរាជរដ្ឋាភិបាល ក្នុងការបិទបញ្ចប់យុទ្ធនាការជាតិចាក់វ៉ាក់សាំងកូវីដ-១៩ ជុំទី១ តាមរាជធានី-ខេត្តនីមួយៗជាបន្តបន្ទាប់រហូតដល់ការបិទបញ្ចប់យុទ្ធនាការនេះក្នុងក្របខណ្ឌទូទាំងប្រទេស ដែលជាមូលដ្ឋានដ៏សំខាន់សម្រាប់រាជរដ្ឋាភិបាលធ្វើការសម្រេចចិត្តក្នុងការអនុវត្តផែនការ

នានាក្នុងជំហានបន្តបន្ទាប់ទៀត។ បន្ថែមពីនេះ បន្ទាប់ពីការសម្រេចបិទបញ្ចប់យុទ្ធនាការជាតិចាក់វ៉ាក់សាំងកូវីដ-១៩ ជុំទី១, គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស ដោយសហការជាមួយគណៈអភិបាលរាជធានី-ខេត្ត ត្រូវបន្តរៀបចំឱ្យមានទីតាំងសម្រាប់ការផ្តល់សេវាចាក់វ៉ាក់សាំងជូនដល់ប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅតាមមន្ទីរពេទ្យបង្អែកក្រុង-ស្រុក-ខណ្ឌ ឬនៅតាមមណ្ឌលសុខភាព ឬតាមទីតាំងផ្សេងទៀត (ផ្អែកតាមស្ថានភាពនៃភូមិសាស្ត្រជាក់ស្តែងនីមួយៗ) និងត្រូវជូនដំណឹងជាសាធារណៈ ដើម្បីអនុញ្ញាតឱ្យប្រជាជនដែលមិនទាន់បានទទួលការចាក់វ៉ាក់សាំង ដោយមូលហេតុផ្សេងៗ អាចទៅទទួលការចាក់វ៉ាក់សាំងនេះបាន។

ទទួលបានសេចក្តីណែនាំនេះ គ្រប់ក្រសួង-ស្ថាប័ន គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស គណៈអភិបាលរាជធានី-ខេត្ត និងយន្តការដែលមានការពាក់ព័ន្ធផ្សេងទៀត ត្រូវផ្សព្វផ្សាយ និងអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃសៅរ៍ ៥រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>**កន្លែងទទួល៖**</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០២៥ សហវ.

សេចក្តីសម្រេច

ស្តីពី

ការបង្កើតគណៈកម្មការលើកទឹកចិត្ត និងជំរុញផលិតកម្មអំបិល

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

ប្រការ១.-

ត្រូវបានបង្កើតគណៈកម្មការលើកទឹកចិត្ត និងជំរុញផលិតកម្មអំបិល (សរសេរអក្សរកាត់ថា **គផអ**) ដែលមានសមាសភាពដូចខាងក្រោម÷

១- ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប**	រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	ប្រធាន
២- ឯកឧត្តម **ពេជ្រ សម្បត្តិ**	អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	អនុប្រធាន
៣- ឯកឧត្តម **សុន សេងហួត**	អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍	អនុប្រធាន
៤- ឯកឧត្តម **ស៊ាង ថៃ**	រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម	សមាជិក
៥- ឯកឧត្តម **ហ៊ិត ផេង**	អគ្គនាយកនៃអគ្គនាយកដ្ឋានសហគ្រាសធុនតូច និងមធ្យម និង សិប្បកម្ម	សមាជិក
៦- ឯកឧត្តម **ហេង សុខណាង**	អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ	សមាជិក
៧- ឯកឧត្តម **អ៊ុង លុយណា**	អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកា	សមាជិក
៨- ឯកឧត្តម **ជា ភុកហុង**	អគ្គនាយករងនៃអគ្គនាយកដ្ឋានគោលនយោបាយ	សមាជិក
៩- ឯកឧត្តម **សួន ទិដ្ឋា**	ទីប្រឹក្សាក្រសួងពាណិជ្ជកម្ម និងជាប្រធាននាយកដ្ឋានកម្មសិទ្ធបញ្ញា	សមាជិក
១០- លោក **អ៊ុង ឆាយ**	អភិបាលរងនៃគណៈអភិបាលខេត្តកំពត	សមាជិក
១១- លោក **ទៅ សុខា**	អភិបាលរងនៃគណៈអភិបាលខេត្តកែប	សមាជិក
១២- លោក **ឆី សុខុន**	ប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានពន្ធដារ	សមាជិក
១៣- លោក **ម៉ុន ជីន**	ប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា	សមាជិក
១៤- លោក **ញៀម ពុធថុនា**	ប្រធានការិយាល័យនៃអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា	សមាជិក
១៥-លោក **ខួន យ៉ាណា**	ប្រធានការិយាល័យនៃអគ្គនាយកដ្ឋានថវិកា	សមាជិក
១៦- លោក **ស៊ាន លីហេង**	មន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	សមាជិក
១៧- លោក **អ៊ុំ សុខធី**	លេខាធិការក្រុមការងារសម្រាប់កិច្ចប្រជុំ "ច្រកចេញចូលតែមួយ"	លេខាធិការ

ប្រការ២.-

គផអ មានភារកិច្ចដូចខាងក្រោម÷

- សម្របសម្រួលជំរុញការអនុវត្តវិធានការគោលនយោបាយលើកទឹកចិត្ត និងជំរុញផលិតកម្មអំបិលក្នុងកម្រិតបច្ចេកទេស ដើម្បីសុំការសម្រេចពីរាជរដ្ឋាភិបាល
- ពិនិត្យផ្តល់ការលើកទឹកចិត្ត និង កម្មិជាដើមទុនក្នុងការអភិវឌ្ឍផលិតផល និង ការផលិត ការកែច្នៃ ការកែលម្អគុណភាព និង ការវេចខ្ចប់អំបិល
- ជំរុញការអនុវត្តការបញ្ចូលជាតិអ៊ីយ៉ូដទៅក្នុងអំបិល និង ពង្រឹងសមត្ថភាពឃ្លាំងស្តុកអំបិល
- ពិនិត្យ និងជំរុញការវិនិយោគក្នុងសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ដែលកំពុងផលិត និងកែច្នៃអំបិលសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក និងនាំចេញ

- ជំរុញ និងសម្របសម្រួលការបង្កើត និងពង្រឹងសមត្ថភាពសហគមន៍អំបិល ដើម្បីសម្របសម្រួលការងារជំរុញផលិតកម្មអំបិល
- ពិនិត្យផ្តល់មូលនិធិ (Seed Fund) ក្នុងទំហំសមស្រប ដល់សហគមន៍អំបិល ដើម្បីធ្វើប្រតិបត្តិការដោយឯករាជ និងចីរភាព
- សិក្សា និង ស្នើដាក់ចេញនូវវិធានការទប់ស្កាត់ការនាំចូលអំបិលដោយខុសច្បាប់
- រៀបចំផែនការថវិកាឱ្យបានច្បាស់លាស់ សមស្រប និងមានសង្គតិភាព ដើម្បីបំពេញភារកិច្ច និង អនុវត្តវិធានការគោលនយោបាយលើកទឹកចិត្ត និង ជំរុញផលិតកម្មអំបិល រួចសុំការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារ និង សុំការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងរាជរដ្ឋាភិបាល
- បំពេញភារកិច្ចដទៃទៀតតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រការ៣.-

ប្រធាន គផអ ទទួលខុសត្រូវរួមក្នុងការដឹកនាំ គផអ និង ដឹកនាំកិច្ចប្រជុំ ។ ប្រធានអាចចាត់តាំងអនុប្រធាន ឬ សមាជិក គផអ ដឹកនាំការងារជំនួស ក្នុងករណីចាំបាច់ ឬ ប្រធានអវត្តមាន ។

គផអ មានសិទ្ធិអញ្ជើញក្រសួងស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន ចូលរួមប្រជុំតាមការចាំបាច់ ។

គផអ មានសិទ្ធិប្រើប្រាស់ត្រាក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុដើម្បីបំពេញភារកិច្ចរបស់ខ្លួន ។

ប្រការ៤.-

គផអ មានលេខាធិការដ្ឋានមួយ ជាសេនាធិការ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ។ លេខាធិការធិការដ្ឋាននេះមានសមាសភាពដូចខាងក្រោម÷

១- លោក **អ៊ុម សុខធី**	លេខាធិការក្រុមការងារសម្រាប់កិច្ចប្រជុំ "ច្រកចេញចូលតែមួយ"នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	ប្រធាន
២- ឯកឧត្តម **ហ៊ិត ឆេង**	អគ្គនាយកនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍	អនុប្រធាន
៣- លោក **ហួន សុខម៉ី**	ប្រធាននាយកដ្ឋានកិច្ចការសិប្បកម្មនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍	សមាជិក
៤- លោក **សៀង ចំណាន**	អនុប្រធាននាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	សមាជិក
៥- លោក **យិន ម៉ិនអាន**	ប្រធានមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្តកំពត	សមាជិក
៦- លោក **កែវ ហុង**	ប្រធានមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្តកែប	សមាជិក
៧- លោក **សុខ គឹមជឿន**	ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ ខេត្តកំពត	សមាជិក

៨- លោក **ម៉ិន យោធ**	ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកែប	សមាជិក
៩- លោក **ស្រី កុម្ភៈ**	ប្រធានមន្ទីរពាណិជ្ជកម្មខេត្តកំពត	សមាជិក
១០- លោក **ឯម រតន៍មុន្នី**	ប្រធានមន្ទីរពាណិជ្ជកម្មខេត្តកែប	សមាជិក
១១- លោក **ឆាន់ តេត**	មន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	សមាជិក

ប្រការ៥.-

លេខាធិការដ្ឋាន គផអ មានភារកិច្ចដូចខាងក្រោម÷

- ធានាកិច្ចដំណើរការប្រចាំថ្ងៃ និងរៀបចំកិច្ចប្រជុំរបស់ គផអ
- សិក្សា និងប្រមូលធាតុចូលសម្រាប់ គផអ
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារ
- បំពេញភារកិច្ចផ្សេងទៀតតាមការសម្រេចរបស់ប្រធាន គផអ ។

ប្រការ៦.-

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាអគ្គនាយក នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយក អគ្គាធិការ នាយកវិទ្យាស្ថាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃសុក្រ ១៥កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ២០២១

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

កន្លែងទទួល÷

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០២៦ សហវ.

សេចក្តីសម្រេច
ស្តីពី
ការបង្កើតគណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ជូនប្រជាពលរដ្ឋ ដើម្បីអនុវត្តគម្រោងនានា របស់អាជ្ញាធរជាតិអប្សរា

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តិនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តិ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២០/២០៣ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការបង្កើតអាជ្ញាធរជាតិអប្សរាជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

ប្រការ១.-

បង្កើតគណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ជូនប្រជាពលរដ្ឋ ដើម្បីអនុវត្តគម្រោងនានារបស់អាជ្ញាធរជាតិអប្សរា ដែលមានសមាសភាពដូចខាងក្រោម÷

១	ឯកឧត្តម **ឈន សុភាព**	រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	ប្រធាន
២	ឯកឧត្តម **ហង់ ពៅ**	អគ្គនាយកអាជ្ញាធរជាតិអប្សរា	អនុប្រធាន
៣	ឯកឧត្តម **ឈី សំរិទ្ធ**	អភិបាលរងរដ្ឋបាលខេត្តសៀមរាប	សមាជិក
៤	ឯកឧត្តម **ឈី សែ**	អគ្គនាយកគ្រឹះស្ថានអង្គរ	សមាជិក
៥	ឯកឧត្តម **ឃិត ចាន់ជារដ្ឋ**	អគ្គនាយករងអាជ្ញាធរជាតិអប្សរា	សមាជិក
៦	ឯកឧត្តម **ឡុង កុសល**	អគ្គនាយករងអាជ្ញាធរជាតិអប្សរា	សមាជិក
៧	ឯកឧត្តម **ខូយ គីមទួ**	ទីប្រឹក្សាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	សមាជិក
៨	លោក **ឌុច បញ្ញាបញ្ញា**	ប្រធាននាយកដ្ឋានហិរញ្ញកិច្ច និងគណនេយ្យនៃអាជ្ញាធរជាតិអប្សរា	សមាជិក
៩	លោក **ណារ ពិសិដ្ឋ**	ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តសៀមរាប	សមាជិក

ប្រការ២.-

គណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ជូនប្រជាពលរដ្ឋដើម្បីអនុវត្តគម្រោងនានារបស់អាជ្ញាធរជាតិអប្សរា មានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- ពិនិត្យវាយតម្លៃលើផលប៉ះពាល់ទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋនៅលើទីតាំងគម្រោងពង្រីកចំណតរថយន្តនៅមុខប្រាសាទអង្គរវត្ត និងគម្រោងសាងសង់ផ្លូវប្រវែង ១៧១ម៉ែត្រ ទទឹង៩ម៉ែត្រ ចាប់ពីកសិន្ធុអង្គរខាងត្បូងទៅដល់ផ្លូវក្ងូម៉ៃ
- ពិនិត្យ និងសម្រេចលើការផ្តល់ប្រាក់គោលនយោបាយ ដោះស្រាយផលប៉ះពាល់ជូនប្រជាពលរដ្ឋ ដោយត្រូវអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដើម្បីឱ្យអាជ្ញាធរជាតិអប្សរា អាចអនុវត្តគម្រោងទាំងនោះបានដោយរលូន និងជោគជ័យ
- ពិនិត្យ និងសម្រេចលើការផ្តល់ប្រាក់គោលនយោបាយជូនគ្រួសារនគរបាលការពារបេតិកភណ្ឌខេត្តសៀមរាប ចំនួន ៨គ្រួសារ ដែលបានស្នាក់នៅក្នុងទីបញ្ជាការចាស់។

ប្រការ៣.-

គណៈកម្មការអន្តរក្រសួងដើម្បីដោះស្រាយផលប៉ះពាល់ជូនប្រជាពលរដ្ឋក្នុងការអនុវត្តគម្រោងនានារបស់អាជ្ញាធរជាតិអប្សរា មានភារកិច្ចរាយការណ៍ពីវឌ្ឍនភាពការងាររបស់ខ្លួន ជូន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីជ្រាប ពិនិត្យ និងសម្រេច ទៅតាមដំណាក់កាលនីមួយៗ។

ប្រការ៤.-

អនុប្រធាន និងសមាជិកត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ គណៈកម្មការអន្តរក្រសួងដើម្បីដោះស្រាយផលប៉ះពាល់ជូនប្រជាពលរដ្ឋក្នុងការអនុវត្តគម្រោងនានារបស់អាជ្ញាធរជាតិអប្សរា មានសិទ្ធិប្រើត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់បំពេញការងារក្នុងក្របខ័ណ្ឌនៃសេចក្ដីសម្រេចនេះ និងមានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា ចូលរួមប្រជុំដើម្បីអនុវត្តការងារតាមការចាំបាច់។

ប្រការ៥.-

ក្នុងករណីចាំបាច់ គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិបង្កើតក្រុមការងារបច្ចេកទេស ធ្វើជាលេខាធិការ ដើម្បីសម្របសម្រួលដោះស្រាយផលប៉ះពាល់ដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ។

ប្រការ៦.-

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាអគ្គនាយក នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយក អគ្គាធិការ នាយកវិទ្យាស្ថាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវអនុវត្តសេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២១

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល៖
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- អាជ្ញាធរជាតិអប្សរា
- រដ្ឋបាលខេត្តសៀមរាប
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: [illegible]

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤(?) ខែវិច្ឆិកា(?) ឆ្នាំ២០២០

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ១៨៤៦/១១ គ.វ.ក ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រកិនស្រូវ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ហ្គោហុង (ខេមបូឌា) អ៊ិនដាសស្ទ្រី

សម្រេច

ប្រការ១៖ អនុញ្ញាតឱ្យក្រុមហ៊ុន ហ្គោហុង (ខេមបូឌា) អ៊ិនដាសស្ទ្រី (**GUOHONG (CAMBODIA) INDUSTRY CO., LTD.**) តំណាងដោយលោក **LI, PINLIN** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខE35651386 ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ បង្កើតរោងចក្រកិនស្រូវ ដែលមានទីតាំងស្ថិតនៅផ្លូវជាតិលេខ៥៤ ភូមិស្ពានពោធិ៍ ឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។

ឈ្មោះផលិតផល	**លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code
អង្ករ	១០៦១

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖" **រោងចក្រកិនស្រូវ ហ្គោហុង (ខេមបូឌា) អ៊ិនដាសស្ទ្រី** "

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពី វិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបាន ឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការ របស់រោងចក្រ ស្របតាមមាត្រា ៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា ១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤៖ ប្រកាសបង្កើតរោងចក្រលេខ០២៤ ឧស.កឧ.ប្រក.០១ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៧ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ១៥៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ ខេត្តកំពង់ឆ្នាំង និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

ប្រការ១៦៖ ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍
រដ្ឋលេខាធិការ

មាន សុភា

ចម្លងជូន៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-រាជកិច្ច
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលាខេត្តកំពង់ឆ្នាំង
-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកំពង់ឆ្នាំង
-រដ្ឋបាលស្រុកសាមគ្គីមានជ័យ
-រដ្ឋបាលឃុំសេដ្ឋី
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ:.. ថ្ងៃ.......................... ខែ.............. ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.............. ខែ.............. ឆ្នាំ២០២០

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ២៤៤៦/៩៩ គ.វ.ក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រផលិតកំណាត់ ផលិតផលចាក់អំពីកប្បាស សម្លៀកបំពាក់ កន្សែងពោះគោ ក្លួយ និងសម្ភារៈផលិតពីកំណាត់ សំរាប់មន្ទីរពេទ្យ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ របស់ក្រុមហ៊ុន មេតថេក (ខេមបូឌា) ខប លីមីធីត

សម្រេច

ប្រការ១៖ អនុញ្ញាតឱ្យក្រុមហ៊ុន **មេតថេក (ខេមបូឌា) ខប លីមីធីត (MEDTECS (CAMBODIA) CORP LIMITED.)** តំណាងដោយលោក **CLEMENT K C YANG** សញ្ជាតិអាមេរិក (ចិន) កាន់លិខិតឆ្លងដែនលេខ531140521 ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៦ បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ និងតម្បាញក្លួយ ដែលមានទីតាំងស្ថិតនៅអតីតរោងចក្រតម្បាញកំពង់ចាម ភូមិអំពិលលើ ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម។

ឈ្មោះផលិតផល	**លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code**
១- សម្លៀកបំពាក់	១៤១០
២- កូយ	១៣៩២

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្ដីណែនាំស្ដីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖" **រោងចក្រតម្បាញកូយ និងកាត់ដេរសម្លៀកបំពាក់ មេតថេក (ខេមបូឌា) ខបលីមីធីត** "

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្ដើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្ដូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្ដូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្ដូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្ដាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពី វិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបាន ឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការ របស់រោងចក្រ ស្របតាមមាត្រា ៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា ១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤៖ ប្រកាសបង្កើតរោងចក្រលេខ៨៧៩ ឧស.កឧ.ប្រក.០៩ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ១៥៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកំពង់ចាម និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

ប្រការ១៦៖ ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

រដ្ឋលេខាធិការ

ហ៊ាន សុភា

ចម្លងជូន៖

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-រាជកិច្ច
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលាខេត្តកំពង់ចាម
-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកំពង់ចាម
-រដ្ឋបាលស្រុកកំពង់សៀម
-រដ្ឋបាលឃុំអំពិល
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: [illegible] ថ្ងៃ[illegible] ខែ[illegible] ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០២០

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ៣៦៨៨/០៣ គ.វ.ក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងប្តូរប្រកាសបង្កើតរោងចក្រថ្មី ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ជីឌីអឹម អ៊ិនធើប្រាយ

សម្រេច

ប្រការ១៖ អនុញ្ញាតឱ្យក្រុមហ៊ុន **ជីឌីអឹម អ៊ិនធើប្រាយ (GDM ENTERPRISE CO., LTD.)** តំណាងដោយលោក **YANG, CHUNAN** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ EA5469980 ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៧ បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅស្មើឧស្សាហកម្មវឌ្ឍនៈ អគារD ភូមិត្រពាំងថ្លឹង១ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

ឈ្មោះផលិតផល	**លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code
សម្លៀកបំពាក់	១៤១០

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្ដីណែនាំស្ដីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។
ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រកាត់ដេរសម្លៀកបំពាក់ ជីឌីអឹម អ៊ិនធើប្រាយ** "

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្ដើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្ដូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្ដូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្ដូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្ដាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រេប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤៖ ប្រកាសបង្កើតរោងចក្រលេខ១០៩ ឧរថ.កឧ.ប្រក. ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៤ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងលិខិតលេខ៥២៤៧ ឧវបន.កឧ.លស.១១ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ១៥៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការ រៀងៗខ្លួន។

ប្រការ១៦៖ ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍
រដ្ឋលេខាធិការ

ហាន សុតា

ចម្លងជូន៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- រាជកិច្ច
- វិទ្យាស្ថានស្តង់ដារកម្ពុជា
- មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- សាលារាជធានីភ្នំពេញ
- មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ
- រដ្ឋបាលខណ្ឌពោធិ៍សែនជ័យ
- រដ្ឋបាលសង្កាត់ចោមចៅទី១

"ដើម្បីជូនជ្រាប"
- ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ:.................................. ថ្ងៃ.................... ខែ.............. ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.......... ខែ.......... ឆ្នាំ២០២០

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ១៤៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការបំបែកសង្កាត់ទួលសង្កែនៃខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
- យោងលិខិតលេខ២៦៩៥/០៩ គ.វ.ក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រផលិតស្រាបៀរ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ក្រុមហ៊ុន យីងដឹម ប្រ៊ូវើរី (ខេមបូឌា) លីមីធីត

សម្រេច

ប្រការ១៖ អនុញ្ញាតឱ្យក្រុមហ៊ុន យីងដឹម ប្រ៊ូវើរី (ខេមបូឌា) លីមីធីត **(KINGDOM BREWERIES (CAMBODIA) LIMITED.)** តំណាងដោយលោក **DOUGLAS WILTSHIRE CLAYTON** សញ្ជាតិអាមេរិក កាន់លិខិតឆ្លងដែនលេខ488882196 ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ បង្កើតរោងចក្រផលិតស្រាបៀរ ដែលមានទីតាំងស្ថិតនៅផ្លូវជាតិលេខ៥ ដីឡូត៍លេខ១៧៤៨ ភូមិឬស្សីស្រស់ សង្កាត់ទួលសង្កែទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

ឈ្មោះផលិតផល	**លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code**
ស្រាបៀរ	១១០៣

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖" រោងចក្រផលិតស្រាបៀរ យើងដឹម ប្រ៊ូវើរី (ខេមបូឌា) លីមីធីត "

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្ដីពី វិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបាន ឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្ដិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការ របស់រោងចក្រ ស្របតាមមាត្រា ៤១ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្ដល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា ១៥ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្ដន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤៖ ប្រកាសបង្កើតរោងចក្រលេខ៣៨៧ ឧស.កឧ.ប្រក.០៨ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៧ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ១៥៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

ប្រការ១៦៖ ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍
រដ្ឋលេខាធិការ

មាន សុភា

ចម្លងជូន៖
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- រាជកិច្ច
- វិទ្យាស្ថានស្តង់ដារកម្ពុជា
- មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- សាលារាជធានីភ្នំពេញ
- មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ
- រដ្ឋបាលខណ្ឌឫស្សីកែវ
- រដ្ឋបាលសង្កាត់ទួលសង្កែទី១
  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: [illegible]

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២០

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ៣៣៣/១២ ត.ត.ស.ព ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១២ ស្តីពីការវិនិយោគបង្កើតរោងចក្រផលិតថង់ប្លាស្ទិក របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ហ្វូភែក (ខេមបូឌា) អេនធើប្រាយ ខបភើរេសិន

សម្រេច

ប្រការ១៖ អនុញ្ញាតឱ្យក្រុមហ៊ុន ហ្វូភែក (ខេមបូឌា) អេនធើប្រាយ ខបភើរេសិន (FOPACK (CAMBODIA) ENTERPRISE CORPORATION.) តំណាងដោយលោក CHEN, YI-MIN សញ្ជាតិចិន(តៃវ៉ាន់) កាន់លិខិតឆ្លងដែនលេខ 305644930 ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១២ បង្កើតរោងចក្រផលិតថង់ប្លាស្ទិក ដែលមានទីតាំងស្ថិតនៅតំបន់សេដ្ឋកិច្ចពិសេសតាយសេងបាវិត (សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង)។

ឈ្មោះផលិតផល	**លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code
ថង់ប្លាស្ទិក	២២២០

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ **"រោងចក្រផលិតថង់ប្លាស្ទិក ហ្វូតេក (ខេមបូឌា) អេនធើប្រាយ ខបភើរេសិន "**

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា ១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤៖ ប្រកាសបង្កើតរោងចក្រលេខ៤១០ ឧស.កឧ.ប្រក.០៨ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ១៥៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តស្វាយរៀង និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការ រៀងៗខ្លួន។

ប្រការ១៦៖ ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍
រដ្ឋលេខាធិការ

ហាន សុភា

ចម្លងជូន៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- រាជកិច្ច
- វិទ្យាស្ថានស្តង់ដារកម្ពុជា
- មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- សាលាខេត្តស្វាយរៀង
- មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តស្វាយរៀង
- អង្គភាពរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសតាមសេងបាវិត
- រដ្ឋបាលក្រុងបាវិត
- រដ្ឋបាលសង្កាត់បាវិត

  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខៈ ០២០៧.១៨.រស.ប្រក.ប្រក

ប្រកាស
ស្ដីពី
លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
លេខ ០២០៧.១៨.រស.ប្រក.ឈរេ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០២០

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ចុះថ្ងៃទី០៩ ខែធ្នូឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បកចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រកចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការផ្ដល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រកចុះថ្ងៃទី០៣ខែកុម្ភៈឆ្នាំ២០១៧របស់ក្រសួងរ៉ែនិងថាមពលនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រកចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្ដីពីការផ្ដល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសារាចរលេខ ០១៤០ រថ.អប្រក.សរចចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០ របស់លោក **ឈន់ សីហា**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

សម្រេច

ប្រការ១.-

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ យីហោ **អិល អេច អរ** ស្ថិតនៅភូមិ៣ ឃុំស្រែអង្គ្រង ស្រុកកូនមុំ ខេត្តរតនគិរី របស់លោក **ឈន់ សីហា** (ម្ចាស់ស្ថានីយ)។

ប្រការ២.-

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

ប្រការ៣.-

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រកចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ស្តីពីនីតិវិធី នៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពលដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោមក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

១. លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី
២. លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រការ៤.-

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមសារាចរលេខ០១៤០ រថ.អប្រក.សរចចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពលដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ នូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. មិនអនុញ្ញាតឱ្យមានបន្ទប់ស្នាក់នៅក្នុងបរិវេណស្ថានីយ
២. មិនត្រូវធ្វើការផ្ទេរប្រេងឥន្ធនៈពីរថយន្តស៊ីទែន ទៅពោងតាមរយៈ ម៉ាស៊ីនគោយន្ត
៣. ពោងសម្រាប់ទុកដាក់ប្រេងឥន្ធនៈ គ្រប់ប្រភេទនៅក្នុងស្ថានីយ ត្រូវកប់ក្រោមដីទាំងអស់ និង ត្រូវស្ថិតនៅទីកន្លែងដែលមានខ្យល់បក់ផាត់ល្អ
៤. បំពង់ខ្យល់ត្រូវមានកម្ពស់អប្បបរមា ៤ ម៉ែត្រ និងស្ថិតក្នុងទីកន្លែងដែលមានខ្យល់បក់ផាត់ល្អ
៥. ត្រូវមានកបំពង់ទទួលប្រេងឥន្ធនៈ
៦. ទូចាក់ប្រេងឥន្ធនៈមានចម្ងាយអប្បបរមា៦ ម៉ែត្រ ឃ្លាតពីអគារការិយាល័យ
៧. ត្រូវបំពាក់គន្លឹះអាសន្ននៅតាមទូចាក់ប្រេងឥន្ធនៈនីមួយៗ និងគន្លឹះអាសន្នរួម
៨. ទុយោចាក់ប្រេងត្រូវមានប្រវែងអតិបរមា៦ ម៉ែត្រ
៩. ត្រូវមានប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក
១០. ត្រូវមានឧបករណ៍បង្ការ និងពន្លត់អគ្គិភ័យឱ្យបានគ្រប់គ្រាន់
១១. ត្រូវមានផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេង
១២. ត្រូវមានស្លាកសញ្ញាបម្រាមស្តីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់
១៣. ត្រូវមានគំនូសសញ្ញាសម្រាប់ចំណតរថយន្តផ្ទេរប្រេងឥន្ធនៈ។

ប្រការ៥...

ម្ចាស់ស្ថានីយត្រូវគោរព តាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

ប្រការ៦...

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ មកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាព នៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

ប្រការ៧...

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពល។

ប្រការ៨.-

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណង អនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយឱ្យមានប្រសិទ្ធិភាពខ្ពស់។

ប្រការ៩.-

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន អំពីហានិភ័យផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

ប្រការ១០.-

ម្ចាស់ស្ថានីយ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ មកអគ្គនាយកដ្ឋានប្រេងកាត នៃក្រសួងរ៉ែនិងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិចមុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

ប្រការ១១.-

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ.០២០៧.១៨.១៦ ប្រក.ណរអ.....ចុះថ្ងៃទី...១៣..............ខែ.កក្កដា.......ឆ្នាំ២០២០...............របស់ក្រសួងរ៉ែនិងថាមពលនិងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះនិងបទប្បញ្ញត្តិជាធរមាន។

ប្រការ១២.-

ក្នុងករណីស្ថានីយនេះ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ) ខែឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើនោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០២០៧.១៨.១៦ ប្រក.ណរអ ចុះថ្ងៃទី.១៣.........ខែ..កក្កដា.........ឆ្នាំ២០២០....នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

ប្រការ១៣.-

នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការប្រធានមន្ទីររ៉ែនិងថាមពលខេត្តរតនគិរី និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ៥...៨រោច.....ខែអាសាឍ...ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...១៣.......ខែ..កក្កដា.......ឆ្នាំ២០២០

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

ស៊ុយ_សែម

កន្លែងទទួល:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលាខេត្តរតនគិរី
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០២០៩.រ៉ែ.អប្រក.ប្រក

ប្រកាស
ស្តីពី
លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ
លេខ ០២០៩.រ៉ែ.អប្រក.សារ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០២០

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បកចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈនិងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ ១២៨សហវ.ប្រកចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ របស់លោក **អ៊ឹង វ៉េងគ័ង**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

សម្រេច

ប្រការ១.-

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈយីហោ **លឹម ឡុង ច្បារមន** ស្ថិតនៅភូមិក្រាំងពលទេព សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ របស់លោក **អ៊ឹង វ៉េងគ័ង (ម្ចាស់ស្ថានីយ)**។

ប្រការ២.-

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

ប្រការ៣.-

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រកចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ស្តីពីនីតិវិធី នៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល។

ប្រការ៤.-

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមសារាចរលេខ០១៤០ រថ.អប្រក.សរចចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពលដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ នូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. មិនអនុញ្ញាតឱ្យមានលំនៅដ្ឋាននៅក្នុងបរិវេណស្ថានីយ
២. ពោងប្រេងឥន្ធនៈមួយត្រូវមានបំពង់ខ្យល់មួយ

៥៧

៣ មិនអនុញ្ញាតឱ្យបញ្ចូលឧស្ម័នឥន្ធនៈដាក់ធុងក្នុងបរិវេណស្ថានីយ
៤. ពោងសម្រាប់ទុកដាក់ប្រេងឥន្ធនៈគ្រប់ប្រភេទនៅក្នុងស្ថានីយត្រូវកប់ក្រោមដីទាំងអស់
៥. ពោងឧស្ម័នឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ២,៥០ម៉ែត្រពីព្រំដីស្ថានីយ
៦. ពោងឧស្ម័នឥន្ធនៈមួយមិនត្រូវមានចំណុះលើសពី១០តោន
៧. ទូចាក់ឧស្ម័នឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៧,៥ម៉ែត្រពីពោងឧស្ម័នឥន្ធនៈ
៨. ទូចាក់ឧស្ម័នឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ម៉ែត្រពីព្រំដីស្ថានីយ
៩. ត្រូវបំពាក់គន្លឹះអាសន្ននៅតាមទូចាក់ប្រេងឥន្ធនៈនីមួយៗ និងគន្លឹះអាសន្នរួម
១០. ទុយោចាក់ប្រេង និងឧស្ម័នឥន្ធនៈមិនត្រូវមានប្រវែងលើសពី៦ម៉ែត្រ
១១. ត្រូវមានគូសគំនូសសញ្ញាសម្រាប់ចំណតរថយន្តផ្ទេរប្រេង និងឧស្ម័នឥន្ធនៈ
១២. ត្រូវមានប្រព័ន្ធញែកសំណល់ រឹង ប្រេង និងទឹក
១៣. ត្រូវមានស្លាកសញ្ញាបម្រាម និងផ្ទាំងព័ត៌មានស្ដីពីនីតិវិធីនៃការផ្ទេរប្រេង និងឧស្ម័នឥន្ធនៈ។

ប្រការ៥.-

ម្ចាស់ស្ថានីយត្រូវគោរព តាមសេចក្ដីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

ប្រការ៦.-

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរ មកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាព នៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

ប្រការ៧.-

ម្ចាស់ស្ថានីយត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្ដាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្ដាហ៍ទី១ នៃឆ្នាំបន្ទាប់មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពល។

ប្រការ៨.-

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយឱ្យមានប្រសិទ្ធិភាពខ្ពស់។

ប្រការ៩.-

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន អំពីហានិភ័យផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

ប្រការ១០.-

ម្ចាស់ស្ថានីយ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ មកអគ្គនាយកដ្ឋានប្រេងកាត នៃក្រសួងរ៉ែនិងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិចមុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

ប្រការ១១.-

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ.០២០៩.ឧប.អប្រក.លរ........ចុះថ្ងៃទី..១៣..............ខែ.កក្កដា......ឆ្នាំ២០២០.............របស់ក្រសួងរ៉ែនិងថាមពលនិងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះនិងបទប្បញ្ញត្តិជាធរមាន។

ប្រការ១២.-

ក្នុងករណីស្ថានីយនេះ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ) ខែឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើនោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០២០៩.ឧប.អប្រក.លរ ចុះថ្ងៃទី..១៣........ខែ.កក្កដា..........ឆ្នាំ២០២០....នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

ប្រការ១៣.-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពលខេត្តកំពង់ស្ពឺ និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ..ចន្ទ.៨.រ.ភ.ច......ខែ.អាសាឍ...ឆ្នាំជូត.ទោស័ក.ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..១៣........ខែ.កក្កដា.......ឆ្នាំ២០២០.

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

ស៊ុយ សែម

កន្លែងទទួល:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលាខេត្តកំពង់ស្ពឺ
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខៈ ០២១១.ឥ.អប្រក.ប្រក

ប្រកាស
ស្តីពី
លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ
លេខ..០២១១..ឥ..អប្រក.ពអ.ចុះថ្ងៃទី..១៣.....ខែ.កក្កដា...ឆ្នាំ ២០២០

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ចុះថ្ងៃទី០៩ ខែធ្នូឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បកចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រកចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រកចុះថ្ងៃទី០៣ខែកុម្ភៈឆ្នាំ២០១៧របស់ក្រសួងរ៉ែនិងថាមពលនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រកចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសារាចរលេខ ០១៤០ រថ.អប្រក.សរចចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ របស់លោកស្រី **ទូច កន្និដ្ឋា**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

សម្រេច

ប្រការ១.

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ យីហោ **តេលា ស្វាយដង្គុំ** ស្ថិតនៅភូមិស្វាយដង្គុំ សង្កាត់ស្វាយដង្គុំ ក្រុងសៀមរាប ខេត្តសៀមរាប របស់លោកស្រី **ទូច កន្និដ្ឋា (ម្ចាស់ស្ថានីយ)**។

ប្រការ២.

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

ប្រការ៣.

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រកចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ស្តីពីនីតិវិធី នៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល។

ប្រការ៤.

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមសារាចរលេខ០១៤០ រថ.អប្រក.សរចចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពលដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ នូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. ត្រូវមានកបំពង់ទទួលប្រេងឥន្ធនៈ
២. ត្រូវមានចំណតសម្រាប់រថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ

៣. ត្រូវមានរបាំងការពារនៅទីតាំងកបំពង់ទទួលឧស្ម័នឥន្ធនៈ
៤. ពោងឧស្ម័នឥន្ធនៈ មិនត្រូវមានចំណុះ លើសពី១០តោន
៥. ត្រូវមានរបងសំណាញ់ដែកការពារព័ទ្ធជុំវិញពោងឧស្ម័នឥន្ធនៈដាក់លើដី
៦. ត្រូវមានស្លាកសញ្ញាស្ដីពីសុវត្ថិភាពនៅក្នុងស្ថានីយឱ្យបានគ្រប់គ្រាន់
៧. ត្រូវមានផ្ទាំងព័ត៌មាន ស្ដីពីនីតិវិធី នៃការផ្ទេរប្រេង និងឧស្ម័នឥន្ធនៈ។

ប្រការ៥.-

ម្ចាស់ស្ថានីយត្រូវគោរព តាមសេចក្ដីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

ប្រការ៦.-

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរ មកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាព នៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

ប្រការ៧.-

ម្ចាស់ស្ថានីយត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្ដាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្ដាហ៍ទី១ នៃឆ្នាំបន្ទាប់មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពល។

ប្រការ៨.-

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយឱ្យមានប្រសិទ្ធិភាពខ្ពស់។

ប្រការ៩.-

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

ប្រការ១០.-

ម្ចាស់ស្ថានីយ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ មកអគ្គនាយកដ្ឋានប្រេងកាត នៃក្រសួងរ៉ែនិងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិចមុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

ប្រការ១១.-

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ.០២១១..រ៉ែ..អរ.ប្រក..ឈរ..ចុះថ្ងៃទី....១៣............ខែ.កក្កដា.....ឆ្នាំ២០.២០.............របស់ក្រសួងរ៉ែនិងថាមពលនិងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះនិងបទប្បញ្ញត្តិជាធរមាន។

ប្រការ១២.-

ក្នុងករណីស្ថានីយនេះ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ) ខែឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើនោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ០២១១.រ៉ែ.អរ.ប្រក.ឈរ ចុះថ្ងៃទី..១៣.......ខែ.កក្កដា........ឆ្នាំ២០.២០...នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

ប្រការ១៣.-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការប្រធានមន្ទីររ៉ែនិងថាមពលខេត្តសៀមរាប និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.ច័ន្ទ..៨.រោច....ខែ.បឋមាសាឍ.ឆ្នាំ.ជូត.ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..១៣.......ខែ.កក្កដា......ឆ្នាំ២០២០
រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

ស៊ុយ សែម

កន្លែងទទួល:
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-សាលាខេត្តសៀមរាប
-ដូចប្រការ១៣
-រាជកិច្ច
-ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខៈ ០៤១៣.អ៥.រស.ប្រក.ប្រក

ប្រកាស

ស្តីពី

លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ

លេខ ០៤១៣.អ៥.រស.ប្រក.លរ. ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០២០

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ចុះថ្ងៃទី០៩ ខែធ្នូឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បកចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រកចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រកចុះថ្ងៃទី០៣ខែកុម្ភៈឆ្នាំ២០១៧របស់ក្រសួងរ៉ែនិងថាមពលនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រកចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសារាចរលេខ ០១៤០ រថ.អប្រក.សរចចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ របស់លោកស្រី **យ៉ែម ឆវ៉ន**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

សម្រេច

ប្រការ១.-

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ យីហោ **ដេប៉ូរតេលា យ៉ែម ឆវ៉ន** ស្ថិតនៅភូមិសំព័រ ឃុំតាអុង ស្រុកចំការលើ ខេត្តកំពង់ចាម របស់លោកស្រី **យ៉ែម ឆវ៉ន (ម្ចាស់ស្ថានីយ)**។

ប្រការ២.-

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

ប្រការ៣.-

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រកចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ស្តីពីនីតិវិធី នៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពលដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោមក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រការ៤.-

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមសារាចរលេខ០១៤០ រថ.អប្រក.សរចចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពលដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ នូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. មិនអនុញ្ញាតឱ្យមានលំនៅដ្ឋានក្នុងបរិវេណស្ថានីយ
២. ត្រូវមានកបំពង់ទទួលប្រេងឥន្ធនៈ
៣. ពោងប្រេងឥន្ធនៈមួយដាក់ប្រេងឥន្ធនៈបានតែមួយប្រភេទប៉ុណ្ណោះ
៤. ត្រូវមានគន្លឹះអាសន្នរួម
៥. ត្រូវមានប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក
៦. ត្រូវសង់របងជញ្ជាំងបាំងជិត កំពស់អប្បបរមា៣ម៉ែត្រ នៅខាងព្រំដីស្ថានីយដែលមានលំនៅដ្ឋានប្រជាពលរដ្ឋ។

ប្រការ៥.-

ម្ចាស់ស្ថានីយត្រូវគោរព តាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

ប្រការ៦.-

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ មកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាព នៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

ប្រការ៧.-

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពល។

ប្រការ៨.-

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយឱ្យមានប្រសិទ្ធិភាពខ្ពស់។

ប្រការ៩.-

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

ប្រការ១០.-

ម្ចាស់ស្ថានីយ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ មកអគ្គនាយកដ្ឋានប្រេងកាត នៃក្រសួងរ៉ែនិងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិចមុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

ប្រការ១១.-

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ.០២១៣.ទខ.ររ.ប្រក.លរ.ន........ចុះថ្ងៃទី..១៣..............ខែ.កក្កដា.......ឆ្នាំ២០២០...............របស់ក្រសួងរ៉ែនិងថាមពលនិងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះនិងបទប្បញ្ញត្តិជាធរមាន។

ប្រការ១២.-

ក្នុងករណីស្ថានីយនេះ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ) ខែឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើនោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ០២១៣.ទខ.ររ.ប្រក.លរ.ន ចុះថ្ងៃទី..១៣........ខែ.កក្កដា........ឆ្នាំ២០២០....នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

ប្រការ១៣.-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការប្រធានមន្ទីររ៉ែនិងថាមពលខេត្តកំពង់ចាម និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.ចន្ទ..៤..រោច....ខែ.អាសាឍ.ឆ្នាំ.ជូត.ទោស័ក.ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..១៣.......ខែ.កក្កដា.......ឆ្នាំ២០២០
រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

ស៊ុយ សែម

កន្លែងទទួល:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលាខេត្តកំពង់ចាម
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី